01040206

E320/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 12 / 2014
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**


**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី ប៉ា ខុនតា
២-មេធាវី កែវ ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ច័ន្ទ វិចិត្រ
៥-មេធាវី ចេង ប៉េងហាប់
៦-មេធាវី ជួង ជូទី
៧-មេធាវី លី ច័ន្ទតុលា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិច សុទាចា
១០-មេធាវី ពេជ្រ សុរិយា
១១-មេធាវី គង់ ទីលីន
១២-មេធាវី យុង ផានិត
១៣-មេធាវី លឹម វណ្ណា
១៤-មេធាវី សុក ស៊ីផាន់ណា
១៥-មេធាវី ស្រ៊ី គីមយូ
១៦-មេធាវី កុយ នាម
១៧-មេធាវី ឌុច ធីរិទ្ធ
១៨-មេធាវី គឹម ទាសនា
១៩-មេធាវី សួស សាមឿន
២០-មេធាវី ខូន មករា
២១-មេធាវី លឹម អេងតេនៈ
២២-មេធាវី ហុង គីមសួន
២៣-មេធាវី ឯក មាលា
២៤-មេធាវី ឡុង ដារ៉ា
២៥-មេធាវី សួង ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី លៀន ចិន្តា


លេខ : ២១៣៧/គ.ម/១៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៤

**សូមគោរព**

**ឯកឧត្តមប្រធានអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**កម្មវត្ថុ:** ការដាក់ទណ្ឌកម្មលើមេធាវីដែលប្រព្រឹត្តខុសឆ្គងក្នុងពេលប្រកបវិជ្ជាជីវៈមេធាវី ។

**យោង:**
- អនុស្សារណៈ (Memo) លេខ E320 ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ។
- ពាក្យសុំអន្តរាគមន៍ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់លោកមេធាវី សុន អរុណ និងលោកមេធាវី Victor KOPPE ។
- ពាក្យសុំអន្តរាគមន៍ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់លោកមេធាវី គង់ សំអុន ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: អនុលោមតាមមាត្រា ៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គណៈមេធាវីគឺជាអង្គការប្រមូលផ្តុំមេធាវីដែលបានអនុវត្តវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានន័យថាមេធាវីទាំងអស់ដែលបានចុះបញ្ជីនៅគណៈមេធាវី ត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់គណៈមេធាវី ។ គណៈមេធាវីមានតួនាទីការពារ និងលើកកម្ពស់តម្លៃនៃវិជ្ជាជីវៈមេធាវី ធ្វើយ៉ាងណាឱ្យវិជ្ជាជីវៈនេះត្រូវបានអនុវត្តប្រកបដោយគុណភាព និងសេចក្តីថ្លៃថ្នូរស្របតាមវិធានវិជ្ជាជីវៈមេធាវីដែលរួមមាន ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ។ មេធាវីគ្រប់រូបត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាគណៈមេធាវី ក្នុងករណីអនុវត្តបំពានទៅលើវិធានណាមួយខាងលើ ។ នៅពេលដែលមេធាវីណាម្នាក់ប្រព្រឹត្តខុសឆ្គងនៅក្នុងពេលប្រកបវិជ្ជាជីវៈ មេធាវីនោះនឹងត្រូវទទួលរងនូវទណ្ឌកម្មវិន័យពីក្រុមប្រឹក្សាគណៈមេធាវី ដែលជាអង្គភាពមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្ម ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបតាមការគួរ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពអំពីខ្ញុំ ។

ប្រធាន

មេធាវី ប៊ុន ហុន

ចម្លងជូន:
- ក្រុមប្រឹក្សាគណៈមេធាវី
- មេធាវី គង់ សំអុន មេធាវី សុន អរុណ និងមេធាវី Victor KOPPE
- ឯកសារ-កាលប្បវត្តិ